សំណួរទី 1
តើសម្ភារសំណង់ដែលធ្វើឡើងដោយលាយស៊ីម៉ងត៍ជាមួយទឹក និងខ្សាច់ ហើយត្រូវបានប្រើសម្រាប់ជញ្ជាំងនិងកម្រាលបាតនៃគេហដ្ឋាន និងប្រើជាការជាដើមពេលរៀបឥដ្ឋឬឥដ្ឋបេតុង គឺហៅថាអ្វី?

1. បាយអ
2. កំបោរជប៉ុន
3. បេតុង
4. ស្នោអ៊ុយរ៉េតាន(Urethane)រឹង

ចម្លើយ៖ 1

# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 2 ផ្នែកសំណង់ (អនុវត្តន៍សំណង់អគារ)

សំណួរទី 2
តើ "ដែកដោតពុម្ពមូល(round separator)" ដែលប្រើក្នុងការងារពុម្ព គឺជាសម្ភារសម្រាប់ធានាឲ្យបានអ្វី?

1. ភាពរឹងមាំរបស់បេតុង
2. កម្រាស់បេតុងការពារសរសៃដែកនៃកម្រាលបាត
3. កម្រាស់បេតុង
4. ភាពរឹងមាំនៃពុម្ព

ចម្លើយ៖ 3

សំណួរទី 3

សម្ភារក្តារសម្រាប់ការសាងសង់ ដែលម្នាងសិលាដែលជាផ្នែកស្នូលត្រូវបានរុំដោយក្រដាសដើមទាំងសងខាង ហើយត្រូវបានគេប្រើជាចម្បងធ្វើជាសម្ភារស្រទាប់បាតនៃជញ្ជាំង តើហៅថាអ្វី?

1. បន្ទះម្នាងសិលា
2. ក្រដាសបិទជញ្ជាំង
3. ការ៉ូជ័រ
4. ពុម្ពបន្ទះ

ចម្លើយ៖ 1

សំណួរទី 4
ក្នុងការរៀបសរសៃដែកនៃសសរពង្រឹងដោយសរសៃដែក តើអ្វីដែលត្រូវបានភ្ជាប់ក្នុងគោលបំណងពង្រឹងទប់ទល់កម្លាំងកាត់(shear)?

1. ស្លុតសម្រាប់បញ្ជាក់គម្លាតសរសៃដែក
2. ស្លាកសម្គាល់ការកែច្នៃ
3. ដុំកំណល់
4. ដែកកាយ៉េ

ចម្លើយ ៖ 4

សំណួរទី 5
តើទ្វារដែលបិទក្រដាសលើស៊ុមឈើដោយមានភ្ជាប់តែមនិងដៃទាញ ហើយដែលត្រូវបានប្រើដើម្បីខណ្ឌចែកបន្ទប់បែបជប៉ុននិងបន្ទប់បែបជប៉ុន គឺហៅថាអ្វី?

1. ហ្វ៊ូរ៉ាស៊ឺ-ដុ (ទ្វាររាបស្មើ)
2. កាម៉ាឈិ-ដុ(ទ្វារមានគ្រោងឆ្អឹង)
3. ហ្វ៊ូស៊ុម៉ា(ទ្វាររុញហ្វ៊ូស៊ុម៉ាប្រើក្រដាស)
4. ស៊ុមទ្វារបង្អួចលោហៈ

ចម្លើយ ៖ 3

សំណួរទី 6
ចូរជ្រើសរើសអ្វីដែលមិនត្រឹមត្រូវ នៅក្នុងការងារលាបបាញ់ថ្នាំ។

1. អនុវត្តការងារទាំងនៅពេលភ្លៀង
2. មុនចាប់ផ្តើមលាបបាញ់ទ្រនាប់ក្រោម ត្រូវកម្ចាត់ធូលីនិងសំរាម
3. ទុករយៈពេលសមស្របឲ្យថ្នាំស្ងួត
4. អនុវត្តដោយបែងចែកជាបីដំណាក់កាលគឺ ការលាបបាញ់ទ្រនាប់ក្រោម ការលាបបាញ់ទ្រនាប់កណ្តាល ការលាបបាញ់ស្រទាប់លើ

ចម្លើយ៖ 1

សំណួរទី 7
ចូរជ្រើសរើសអ្វីដែលត្រឹមត្រូវ នៅក្នុងការងារដែលប្រើជណ្តើរជ្រែង។

1. ធ្វើការដោយជិះច្រកកៀរលើជណ្តើរជ្រែង
2. ជិះលើថាសជណ្តើររបស់ជណ្តើរជ្រែង
3. ឡើងដោយដៃទាំងពីរមានកាន់អីវ៉ាន់
4. ធ្វើការដោយឈរនៅម្ខាងនៃជណ្តើរជ្រែង

ចម្លើយ៖ 4